## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# វិទ្យាស្ថានវ៉ាន់ដា គណនេយ្យ

VANDA INSTITUTE OF ACCOUNTING

## កិច្ចការស្រាវជ្រាវ

## ប្រធានបទះបាបកម្មទាំង១៥យ៉ាង

## មុខវិជ្ជាះសីលវិជ្ជា

## បង្រៀនដោយសាស្ត្រាចារ្យះ ហ៊ួ សេរីសុជាតា


| | | | |
|---|---|---|---|
| ១.ស៊ិន ម៉ិច | ID B23/3245 | ៦.នី វីសា | ID B23/3221 |
| ២.ភន់ ឆៃអ៊ាង | ID B23/3233 | ៧.ហាន ម៉ារ៉ា | ID B23/3334 |
| ៣.សោន ស្រីនីតា | ID B23/3251 | ៨.ប៉ៃ នីសា | ID B23/3263 |
| ៤.ឆ៉ុក សុនីតា | ID B23/3277 | ៩.ហេង រិទ្ធកល្យាន | ID B23/3264 |
| ៥.អ៊ុង សុពីរីយ៉ា | ID B23/3155 | ១0.សម្បត្តិ ស៊ីណា | ID B23/3214 |


ឆ្នាំទី១ ឆមាសទី១ ជំនាន់ទី២៣ វគ្គ៤

បន្ទប់ះ G5.3 វេនះព្រឹក

ឆ្នាំសិក្សា២០២៤



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានវ៉ាន់ដា**

VANDA INSTITUTE

# ទម្រង់វាយតម្លៃកិច្ចការស្រាវជ្រាវរបស់និស្សិត

Assignment

**ជំនាន់ទី**...២៣...**ថ្នាក់ទី**...៤...**ឆ្នាំទី**...១...**ឆមាស**...១...

**មុខវិជ្ជា**...Ethic

ឈ្មោះប្រធានក្រុម៖ ស៊ិន ម៉ិច

អត្តលេខសមាជិក៖

| | | | | |
|---|---|---|---|---|
| 1.B23/3245 | 3.B23/3251 | 5.B23/3155 | 7.B23/3334 | 9.B23/3264 |
| 2.B23/3233 | 4.B23/3277 | 6.B23/3221 | 8.B23/3263 | 10.B23/3214 |

| **ការវាយតម្លៃ** | **ពិន្ទុ** | **យោបល់សាស្ត្រាចារ្យ** |
|---|---|---|
| **១.ចំណេះដឹង និងជំនាញវិភាគ**<br>(Knowledge and Cognitive)<br>- លំហាត់/សំណួរតាមមេរៀននីមួយៗ<br>- ការឆ្លើយសំណួរមេរៀន<br>- ការស្រាវជ្រាវចងក្រងជាអត្ថបទ/សៀវភៅ<br>- ខ្លឹមសារ អត្ថបទស្រាវជ្រាវ<br>- ប្រភពឯកសារស្រាវជ្រាវ<br>**២.ការធ្វើបទបង្ហាញ**<br>(សម្រាប់មុខវិជ្ជាដែលមានបទបង្ហាញ)<br>➢ សម្លៀកបំពាក់<br>➢ សម្លេង<br>➢ បកស្រាយ<br>➢ ការឆ្លើយសំណួរ<br>➢ សហការណ៍ក្រុម<br>➢ ការគ្រប់គ្រងពេលវេលា<br>**៣.ផ្សេងៗ** | | |
| **ពិន្ទុសរុប** | | |

ថ្ងៃទី      ខែ      ឆ្នាំ២០២៤

**ហត្ថលេខាតំណាងក្រុម/និស្សិត**

ថ្ងៃទី..........ខែ.............ឆ្នាំ២០២៤

**ហត្ថលេខាសាស្ត្រាចារ្យ**

## អារម្ភកថា

ប្រទេសកម្ពុជាជាប្រទេសមួយដែលមាននអរិយធម៌ល្អប្រពៃផ្ទរផង់យ៉ាងល្អប្រសើរ ហើយប្រទេសយើងក៏ជាប្រទេសដែលប្រកាន់យកនូវព្រះពុទ្ធឱវាទ ជា គោល និងគោរពប្រតិបត្តិតាមព្រះពុទ្ធឱវាទនោះខ្ជាប់ខ្ជួន។ ព្រះពុទ្ធជាម្ចាស់នៃយើង ទ្រង់បានត្រាស់ដឹងដោយស្វែងយល់ពីបាបកម្មយ៉ាងល្អិតល្អន់ ហើយបានបន្សល់ ទុកនូវពុទ្ធឱវាទជាច្រើន សម្រាប់ឲ្យយើងជាពុទ្ធសាសនិក យកមកប្រតិបត្តិដើម្បីក សាងជាបុណ្យកុសលផងដែរ ។ តែផ្ទុយទៅវិញយើងមិនគោរពតាម រីបំពានវាប ណ្តានឲ្យកើតមាននូវអកុសលដែលជាហេតុនាំឲ្យមានបាបកម្ម សម្រាប់ជាតិមុខ និងអាចប៉ះពាល់ទាំងក្នុងប្រទេសរួមទាំងការរស់នៅជាមួយ អ្នកជិតខាងផងដែរ ។

ជាធម្មតាការ កើត ចាស់ ឈឺ ស្លាប់ ជារឿងធម្មជាតិរបស់មនុស្សសត្វ ដែលនៅក្នុង ទ្រឹស្តីព្រះពុទ្ធសាសនា ហៅថាទ្រឹស្តីសច្ចៈ ដែលសិក្សាអំពីជីវិតមនុស្សសត្វ។

ពិតណាស់វត្ថុទាំងឡាយតែងតែមានគូនឹងគ្នា មានកើត មានចាស់ មានអាក្រក់ មាន ល្អ មាន ស មានខ្មៅ ដូចនេះអ្វីដែលយើងត្រូវលើកយកមកសិក្សានៅពេលនេះ គឺ យើងសិក្សាអំពីបាបកម្មទាំង ១៥យ៉ាង ដែលមានអវិជ្ជា ជាអ្នកដេកនាំទៅ រកផ្លូវអាក្រក់ ពោល គឺអំពើបាបនេះឯង ដែលព្រះសម្មាសម្ពុទ្ធ

# ឧទ្ទិសកថា

សូមឧទ្ទិសស្នាដៃនេះថ្វាយ និងជូនដល់៖

ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងព្រះវិញ្ញាណក្ខន្ធ ព្រះវិរៈក្សត្រនៃខ្មែរគ្រប់ជំនាន់ វិញ្ញាណក្ខន្ធបុព្វបុរស អ្នកប្រាជ្ញា កវីបណ្ឌិត នឹងវិរៈជនស្នេហាជាតិគ្រប់សម័យកាល ដែលបានបូជាទាំងកម្លាំងកាយ កម្លាំងចិត្តនិងបានលះបង់ រួមទាំងហ៊ានពលីកម្ម ដើម្បីឲ្យជាតិខ្មែរបានគង់វង្សរហូតដល់សព្វថ្ងៃ។

យើងខ្ញុំជាកូនៗ សូមសន្យាថានឹងវៀងចាកឲ្យឆ្ងាយ នៅរាល់អំពើបាប ទាំងឡាយ ហើយកូនៗ នឹងប្រកាន់ភ្ជាប់នូវភាពសច្ចៈ ទៀងត្រង់ និង ព្រមលះបង់ ទាំងកាយវាចាចិត្ត ដែលប្រកបដោយ សុជីវធម៌ គុណធម៌ សីលធម៌ ដើម្បីការពារ ព្រះពុទ្ធសាសនា ឲ្យបាន គង់វង្ស ស្ថិតថេរ យូរអង្វែង រហូតតពីជំនាន់មួយទៅជំនាន់ មួយទៀត ហើយនឹងជាកេរ្តិ៍មរតក បន្សល់ទុកឲ្យអ្នកជំនាន់ក្រោយបាន គោរព ប្រតិបត្តិតាម ដូចពាក្យស្លោកមួយឃ្លាបាន ពោលថា"**ទូកទៅកំពង់នៅ**" ។

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនេះយើងខ្ញុំសូមអរព្រះគុណដល់លោកអ្នកមានគុណទាំងពីរដែល បានផ្តល់កំណើតនិងចំណេះវិជ្ជាឲ្យកូនគ្រប់រូបទាំងប្រុសទាំងស្រីឲ្យបានសិក្សា រៀនសូត្រតាំងពីតូច រហូតដល់ធំពេញវ័យនឹងតាំងពី បឋម បន្តចូលអនុវិទ្យាល័យ វិទ្យាល័យ និងចូលដល់មហាវិទ្យាល័យ ក៏ដូចជាសកលវិទ្យាល័យ បច្ចុប្បន្ននេះ។ ហើយជាបន្ទាប់មកនេះ យើងខ្ញុំសូមថ្លែងអំណរគុណដល់ លោកសាស្ត្រាចារ្យ ហេង វ៉ាន់ដា ដែលលោកបានបង្កើតអោយមាន វិទ្យាស្ថាន វ៉ាន់ដា នេះឡើង ដែល បានធ្វើឲ្យពួកយើងអាចចូលរៀននូវសាលាដ៏ល្អនេះ ហើយបានទទួលនូវចំណេះ ដឹង សុជីវធម៌ សីលធម៌ ដែលប្រកបដោយក្រមសីលធម៌ និងធ្វើជាធនធានមនុស្សដ៏ សំខាន់ ក្នុងការកសាងប្រទេសយើងបន្តទៀត។

ជាចុងបញ្ចប់យើងខ្ញុំទាំងអស់គ្នា សូមថ្លែងអំណរគុណដល់ សាស្ត្រាចារ្យ ហ៊ូ សេរីសុជាតា ដែលបានបង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹង ដែលជាគ្រឹះដ៏សំខាន់ សម្រាប់យើងខ្ញុំទាំងអស់គ្នាយកទៅសិក្សាបន្តនូវថ្ងៃខាងមុខ រហូតទទួលបានជោគ ជយ័នាថ្ងៃអនាគត ដូចប្រធានបទខាងលើនេះផងដែរ។ ហើយក្នុងប្រធានបទនេះ វា មានសារៈសំខាន់ណាស់ក្នុងព្រះពុទ្ធសាសនា ដែលបានអប់រំមនុស្សក្នុងសង្គមយើង បច្ចុប្បន្ននេះ រួមទាំងអត្ថន័យ និងផលប្រយោជន៍ជាច្រើន ដូចជាជួយពញ្រាក់ស្មារតី ទៅមនុស្សទូទៅ ដែលរស់នៅក្នុងសង្គមជាតិឲ្យស្គាល់បុណ្យបាបថាវាមានពិតមែន និងរាជរដ្ឋាភិបាលឲ្យមើលឃើញនូវតម្លៃរបស់ព្រហពុទ្ធសាសនាផងដែរ។

# មាតិកា

**១. មេរៀនទី១៖ បាបកម្មទោសៈ**........................................................................**១**

ក. និយមន័យ ........................................................................................ ១

ខ. ការលេចឡើងនៃទោសៈ.......................................................................... ១

គ. លទ្ធផលនៃទោសៈ ................................................................................ ១

ឃ. សេចក្ដីសន្និដ្ឋាន .................................................................................. ១

**២. មេរៀនទី២៖ បាបកម្ម សន្សំរឿង** ................................................................**២**

ក. និយមន័យ ........................................................................................ ២

ខ. ការលេចឡើងនៃបាបកម្មសន្សំរឿងៈ...................................................... ២

គ. លទ្ធផលនៃបាបកម្មសន្សំរឿង................................................................ ២

ឃ. សេចក្ដីសន្និដ្ឋាន.................................................................................. ២

**៣. មេរៀនទី៣៖ បាបកម្ម រមិលគុណ** ...............................................................**៣**

ក. និយមន័យ........................................................................................ ៣

ខ. ការលេចឡើងនៃរមិលគុណ .................................................................. ៣

គ. លទ្ធផលនៃរមិលគុណ ......................................................................... ៣

ឃ. សេចក្ដីសន្និដ្ឋាន.................................................................................. ៣

**៤. មេរៀនទី៤៖ បាបកម្ម កម្ពស់ខ្លួន**..................................................................**៤**

ក. និយមន័យ........................................................................................ ៤

ខ. ការលេចឡើងនៃបាបកម្មកម្ពស់ខ្លួន ....................................................... ៤

គ. លទ្ធផលនៃបាបកម្មកម្ពស់ខ្លួន................................................................ ៤

ឃ. សេចក្ដីសន្និដ្ឋាន.................................................................................. ៤

**៥. មេរៀនទី៥៖ បាបកម្ម ច្រណែន**....................................................................**៥**

ក. និយមន័យ ........................................................................................ ៥

ខ. ការលេចឡើងនៃបាបកម្មច្រណែន.......................................................... ៥

គ. លទ្ធផលនៃបាបកម្មច្រណែន.................................................................. ៥

ឃ. សេចក្ដីសន្និដ្ឋាន.................................................................................. ៥

**៦. មេរៀនទី៦៖ បាបកម្ម កំណាញ់**....................................................................**៦**

ក. និយមន័យ........................................................................................ ៦

ខ. ការលេចឡើងនៃបាបកម្មកំណាញ់ ........ ៦
គ. លទ្ធផលនៃបាបកម្មកំណាញ់ ........ ៦
ឃ. សេចក្តីសន្និដ្ឋាន ........ ៦
**៧. មេរៀនទី៧៖ បាបកម្មលាក់ទោសកំហុសទុក ........ ៧**
ក. និយមន័យ ........ ៧
ខ. ការលេចឡើងនៃលាក់ទោសកំហុសទុក ........ ៧
គ. លទ្ធផលនៃលាក់ទោសកំហុសទុក ........ ៧
ឃ. សេចក្តីសន្និដ្ឋាន ........ ៧
**៨. មេរៀនទី៨៖ បាបកម្មអួត ........ ៨**
ក. និយមន័យ ........ ៨
ខ. ការលេចឡើងនៃបាបកម្មអួត ........ ៨
គ. លទ្ធផលនៃបាបកម្មអួត ........ ៨
ឃ. សេចក្តីសន្និដ្ឋាន ........ ៨
**៩. មេរៀនទី៩៖ បាបកម្មចចេសរឹងរូស ........ ៩**
ក. និយមន័យ ........ ៩
ខ. ការលេចឡើងនៃបាបកម្មចចេសរឹងរូស ........ ៩
គ. លទ្ធផលនៃបាបកម្មចចេសរឹងរូស ........ ៩
ឃ. សេចក្តីសន្និដ្ឋាន ........ ៩
**១០. មេរៀនទី១០៖ បាបកម្មប្រជែង ........ ១០**
ក. និយមន័យ ........ ១០
ខ. ការលេចឡើងនៃបាបកម្មប្រជែងយកឈ្នះ ........ ១០
គ. លទ្ធផលនៃបាបកម្មប្រជែងយកឈ្នះ ........ ១០
ឃ. សេចក្តីសន្និដ្ឋាន ........ ១០
**១១. មេរៀនទី១១៖ បាបកម្មទុកខ្លួនវិសេសវិសាលជាងគេ ........ ១១**
ក. និយមន័យ ........ ១១
ខ. ការលេចឡើងនៃបាបកម្មទុកខ្លួនវិសេសវិសាលជាងគេ ........ ១១
គ. លទ្ធផលនៃបាបកម្មទុកខ្លួនវិសេសវិសាលជាងគេ ........ ១១
ឃ. សេចក្តីសន្និដ្ឋាន ........ ១១

**១២. មេរៀនទី១២៖ បាបកម្មមើលងាយគេ ..... ១២**
ក. និយមន័យ ..... ១២
ខ. ការលេចឡើងនៃបាបកម្មមើលងាយគេ ..... ១២
គ. លទ្ធផលនៃបាបកម្មមើលងាយគេ ..... ១២
ឃ. សេចក្ដីសន្និដ្ឋាន ..... ១២
**១៣. មេរៀនទី១៣៖ បាបកម្មស្រវឹងលង់ក្នុងគំនិត ..... ១៣**
ក. និយមន័យ ..... ១៣
ខ. ការលេចឡើងនៃបាបកម្មស្រវឹងលង់ក្នុងគំនិត ..... ១៣
គ. លទ្ធផលនៃបាបកម្មស្រវឹងលង់ក្នុងគំនិត ..... ១៣
ឃ. សេចក្ដីសន្និដ្ឋាន ..... ១៣
**១៤. មេរៀនទី១៤៖ បាបកម្មឆ្មេសប្រហែស ..... ១៤**
ក. និយមន័យ ..... ១៤
ខ. ការលេចឡើងនៃបាបកម្មធ្វេសប្រហែស ..... ១៤
គ. លទ្ធផលនៃបាបកម្មធ្វេសប្រហែស ..... ១៤
ឃ. សេចក្ដីសន្និដ្ឋាន ..... ១៤
**១៥. មេរៀនទី១៥៖ បាបកម្មជោរ ..... ១៥**
ក. និយមន័យ ..... ១៥
ខ. ការលេចឡើងនៃបាបកម្មជោរ ..... ១៥
គ. លទ្ធផលនៃបាបកម្មជោរ ..... ១៥
ឃ. សេចក្ដីសន្និដ្ឋាន ..... ១៥
សេចក្ដីសន្និដ្ឋាន
ឯកសារពិគ្រោះ

**មេរៀនទី១                                    បាបកម្មទោសៈ**

**ក. និយមន័យ**

ទោសៈ គឺមានន័យថា កំហឹង សម្អប់ កំហុស ឬមានទោសៈខ្លាំង។

**ខ. ការលិចឡើងនៃទោសៈ**

ទោសៈ គឺកើតឡើងនៅពេល មានកំហឹងទៅលើអ្វីមួយដែលកើតមាននៅក្នុងចិត្តរបស់មនុស្សសត្វ ឬកើតឡើងពីការច្រណែនឈ្នានីស ការចងអាឃាដប៉ុនប៉ងព្យាបាទចំពោះអ្នកដទៃជាដើម ហើយវាអាចធ្វើឱ្យមានបញ្ហាដល់ខ្លួននិងអ្នកដទៃដោយមនុស្សហ៊ានធ្វើអ្វីទាំងអស់ទៅលើអ្នកព្រមទាំងខ្លួនឯងផងដែរទោសៈតែងតែធ្វើឱ្យមនុស្សលែងដឹងអី ដឹងតែចង់ឈ្នះ មិនដឹងខុសត្រូវ មិនមានសីលធម៌ អត់ស្គាល់បុណ្យ បាប ល្អ និងអាក្រក់អ្វីឡើយ។

**គ. លទ្ធផលនៃទោសៈ**

លទ្ធផលនៃទោសៈគឺតែងតែនាំមកនូវភាពអពមង្គល និងធ្វើឱ្យជីវិតជួបតែនូវភាពស្ដាយក្រោយនៅក្នុងចិត្តអស់មួយជីវិតមិនសាបសូន្យឡើយ។

**ឃ. សេចក្ដីសន្និដ្ឋាន**

ដូចនេះមនុស្សគ្រប់រូបគួរតែកាត់បន្ថយឬព្យាយាមលុបបំបាត់នូវទោសៈនៅក្នុងខ្លួនឱ្យបាច្រើនទើបធ្វើឱ្យខ្លួនឯងនិងអ្នកដទៃមានសុភមង្គលតរៀងទៅ។

**មេរៀនទី២** **បាបកម្មសន្សំរឿង**

**ក. និយមន័យ**

ការសន្សំរឿង គឺមានន័យថាជាការប្រមូលផ្ដុំរឿងពីតូចទៅធំ ពីតិចទៅច្រើនគឺចង់និយាយអំពីការប្រមូលផ្ដុំ, សន្សំរឿងរ៉ាវ, បញ្ហា(ជម្លោះ)ផ្សេងៗ ដែលធ្វើឱ្យពិបាកដោះស្រាយនិងស្មុគស្មាញ ធ្វើឱ្យមនុស្សមានរឿងមិនចេះចប់មិនចេះហើយ និងជាអំពើសដីលធម៌មួយដែលនឹងនាំទៅដល់ជម្លោះទាស់ទែង ការបែកបាក់គ្នាព្រមទាំងមិនសូវមានសេចក្ដីល្អក្នុងខ្លួនឡើយ។

**ខ. ការលិចឡើងនៃបាបកម្មសន្សំរឿង**

ការសន្សំរឿង គឺកើតទៅលើមនុស្សដែលមិនចេះស្រលាញ់គ្នា មិនចេះអធ្យាស្រ័យគ្នាទៅវិញទៅមក ហើយវាច្រើនកើតចេញមកពីការពេញចិត្ត, ភាពល្ងង់ខ្លៅ, ការចង់ប្រជែងយកឈ្នះនឹងនរណាម្នាក់ដោយខ្វះការពិចារណា ខ្វះការគិត។

**គ. លទ្ធផលនៃបាបកម្មសន្សំរឿង**

ការសន្សំរឿង គឺគ្មានអ្វីផ្ដល់ផលមកឱ្យល្អៗនោះទេគឺផ្ដល់នូវសេចក្ដីវិនាសតែប៉ុណ្ណោះ គឺគ្មានហេតុផលណាដែលមនុស្សសន្សំរឿងទទួលនូវភាពល្អប្រសើរនោះទេរមែងតែធ្វើឱ្យគេស្អប់,គេមើលងាយ, មិនសូវមានមិត្តភក្ដិ, បាត់បង់ភាពរីករាយសម្បូរសប្បាយ, ពុំសូវមានសេចក្ដីស្រលាញ់ ការគោរព និងសេចក្ដីចម្រើននោះឡើយ។

**ឃ. សេចក្ដីសន្និដ្ឋាន**

សរុបមកការសន្សំរឿងពុំបាននាំមកនូវប្រយោជន៍អ្វីឱ្យអ្នកបាននោះទេដូចនេះមនុស្សម្នាក់ៗគួរតែចៀសវាងនូវបាបកម្មនេះហើយព្យាយាមសាងតែអំពើល្អៗដើម្បីរក្សាសុខសន្តិភាពនិងការអភិវឌ្ឍន៍ព្រមទាំងកសាងចិត្តគំនិតឱ្យបានល្អ។

**មេរៀនទី៣ បាបកម្មរមិលគុណ**

**ក. និយមន័យ**

រមិលគុណ គឺសំដៅទៅលើទង្វើទាំងឡាយណាដែលអាក្រក់ មិនល្អ ការធ្វើមិនដឹងមិនឮ ឬមិនអើពើនឹងអ្នកណាម្នាក់ដែលមានគុណមកលើយើង គឺមានន័យថាគេបានធ្វើអំពើល្អមកលើយើង ប៉ុន្តែបែរជាយើងមិនសងគុណ មិនដឹងគុណគេហើយព្រមទាំងចង់ឃើញគេវិនាសទៀតផង។

**ខ. ការលិចឡើងនៃបាបកម្មរមិលគុណ**

ការរមិលគុណ គឺកើតលើងនៅពេលដែលមនុស្សដឹងគុណមិនសងគុណ, ធ្វើមិនដឹងមិនឮទៅលើមនុស្សដែលគេធ្វើអំពើល្អលើខ្លួន។ មួយវិញទៀតជាមនុស្សដែលរមិលគុណ មិនស្គាល់បុណ្យនិងបាប មិនស្គាល់គុណ មិនស្គាល់ទោសឡើយ។ ម៉្យាងទៀតគឺមិនសូវមានការយល់ដឹងពីអរិយធម៌ កង្វះនូវធម៌កតញ្ញូនៅក្នុងខ្លួនទើបធ្វើឱ្យមនុស្សមានការយល់ខុសថាអ្វីជាគុណ អ្វីទៅជាទោស បែរជាយល់ឃើញសថាខ្មៅ, ឃើញគុណថាទោស មិនតែប៉ុណ្ណោះថែមទាំងនៅតែធ្វើអំពើរមិលគុណនេះឡើងមកទៀត។

**គ. លទ្ធផលនៃបាបកម្មរមិលគុណ**

យើងដឹងហើយថាការរមិលគុណ គឺជាបាបកម្មឬជាអំពើមិនល្អដែលតែងតែផ្តល់មកនូវភាពមិនល្អដល់ខ្លួន ហើយថែមទាំងធ្វើឱ្យគេមិនស្បាយចិត្ត ខកចិត្តជាខ្លាំងដែលឃើញមនុស្សដែលខ្លួនខំជួយបែរជាធ្វើអំពើមិនល្អដាក់ខ្លួន, ធ្វើឱ្យគេស្អប់ខ្ពើម, មានបាបកម្មច្រើន។ ម៉្យាងទៀតតែងតែរស់នៅដោយក្តីរងទុក្ខវេទនាទាំងផ្លូវកាយនិងផ្លូវចិត្តព្រោះចង់សងគុណអ្នកទាំងនោះវិញគឺវាហួសពេលនៅហើយដែលធ្វើឱ្យពួកគេស្តាយក្រោយពេញមួយជីវិតរបស់ពួកគេ។

**ឃ. សេចក្តីសន្និដ្ឋាន**

តាមការបង្ហាញខាងលើការរមិលគុណគឺជាបាបកម្មមួយដែលយើងមិនត្រូវមាននៅក្នុងខ្លួនឡើយគឺដឹងគុណសងគុណទើបវាត្រឹមត្រូវហើយព្យាយាមសាងតែអំពើល្អនៅក្នុងខ្លួននិងព្យាយាមចៀសវាងនូវទង្វើបែបនេះ ដើម្បីអនាគតដែលមានតែភាពរីករាយនិងមិនមានការសោកស្តាយនៅក្នុងជីវិត។

## មេរៀនទី៤ បាបកម្មការលើកកម្ពស់ខ្លួនឯង

### ក. និយមន័យ

ការលើកកម្ពស់ខ្លួនឯងគឺជាការឲ្យតម្លៃលើខ្លួនឯង ខ្ពស់ជាងអ្នកដទៃឯទៀត យល់ថាខ្លួនឯងល្អពូកែ ប្រសើរជាងអ្នកដទៃ បើប្រៀបនឹងអ្នកដទៃខ្លួនល្អជាងគេ។ បើតាមវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិតបានឲ្យដឹងថា ការលើកកម្ពស់ខ្លួនឯងគឺជា ការលើកខ្លួនឯងពីក្រោមឡើងលើ យោងឡើងពីទាប ទៅខ្ពស់ នឹងអ្នកដទៃមិនដល់ខ្លួនជាដើម។ មនុស្សរាប់អានគ្នាតែងតែមានគុណ វិសេសរៀងៗ ខ្លួនៗ ដោយអ្នកខ្លះមានគុណសម្បត្តិច្រើន និង អ្នកខ្លះមានគុណសម្បត្តិតិចទៅតាមការកែខៃតែប៉ុណ្ណោះ។

### ខ. ការលេចឡើងនៃការលើកកម្ពស់ខ្លួនឯង

ការលើកកម្ពស់ខ្លួនឯងលេចឡើងក្នុងរូបភាពដូចជា នៅពេលដែលខ្លួនរៀនពូកែ រាប់អានតែអ្នករៀនពូកែដូចគ្នា មិនរាប់អានឬនិយាយរកអ្នកដែលខ្សោយជាងខ្លួន។ បើធៀបទៅនឹងអ្នករកស៊ី អ្នកដែនមានលុយច្រើនរកស៊ីតែមុខរបធំៗដែលទទួល បានប្រាក់ចំណេញច្រើនៗ មិនរកស៊ីអ្វីដែនជាប់ពាក់ព័ន្ធជាមួយអ្នកដែលក្រជាងខ្លួន ឬមិនដល់ខ្លួនជាដើម។ ចំពោះអាការៈឬសភាលក្ខណៈរបស់មនុស្សដែលលើក កម្ពស់ខ្លួនឯងមានដូចជា មិនចូលចិត្តរាប់អានអ្នកដែលតូច ឬខ្សត់ខ្សោយជាងខ្លួន រស់នៅដាច់ដោយលែចពីគេ ក្រអឺតក្រទម ឆ្មើងឆ្មៃ មិនយកភ្នែកមើលអ្នកដទៃ ជើង ទ្រង់ ចូលចិត្តចាត់ចែង ឬគ្រប់គ្រងលើអ្នកដទៃ តាំងខ្លួនជាមេឬអ្នកដឹកនាំគេគ្រប់ ពេលមិនចង់ឲ្យគេជួយ ព្រោះយល់ថាខ្លួនឯងស្ទីក៏ធ្វើបាន មិនផ្តល់ឪកាសដល់អ្នកដ ទៃ។ល។

### គ. លទ្ធផលនៃការលើកកម្ពស់ខ្លួនឯង

យើងអាចប្រៀបមនុស្សបែបនេះទៅនឹងសត្វមួយប្រភេទ ដែលចូលចិត្តតែភាពអ ស្ងារ្យចំពោះខ្លួនឯង ទើបមានគំនិតមួយថា មានតែអញទេដែលល្អ ប្រសើរ និង ខ្ពង់ខ្ពស់ជាងគេឯងរាល់គ្នា។ ដូចពាក្យចាស់បុរាណលោកបានពោលថា " ភ្នំខ្ពស់ ហើយនៅតែមានស្មៅដុះពីរលើខ្ពស់ជាងភ្នំនោះទៀត " ។ យើងគួរតែគិតថានៅលើ ផែនដីនេះមិនមាននរណាម្នាក់ល្អឥតខ្ចោះទេ នៅតែមានមនុស្សជាច្រើនដែនចេះ ឬ ប្រសើរជាងយើង។ ដូចនេះយើងគួរតែដាក់អស្មិមានចុះ ហើយប្រាប់ខ្លួនឯងថានឹង បោះផ្ទត់គំនិតមួយនេះចោល ដើម្បីកុំឲ្យមានការលើកកម្ពស់ខ្លួនហួសហេតុពេក ទាំងនេះហើយដែលជាកំណើតធ្វើឲ្យកើតមាន សេចក្តីវេទនា នឹង សេចក្តីអន្តរាយ។

## ឃ. សេចក្ដីសន្និដ្ឋាន

សរុបសេចក្ដីមក ការលើកកម្ពស់ខ្លួនឯងជាអំពើមួយដែលមិនគួរធ្វើ នឹងមិនគួរ សូម្បី គិត។ វាគ្រាន់តែជាការបោកបញ្ឆោតរបស់អស្មិមានចិត្តតប៉ុណ្ណោះ ដែលធ្វើ ឲ្យអ្នកដទៃមើលងាយមើលថោកមកលើយើង ហើយការនើកកម្ពស់ខ្លួនឯងក៏មិន មែនជាការល្អណាស់ណាដែរ វាមិនដែលផ្ដល់នៅឧត្តមភាព នឹង សុភមង្គលដល់អ្នក នោះទេ។ ការកើតមកជាមនុស្សជាការកម្រ ដូចនេះយើងត្រូវប្រព្រឹត្តិសុចរិតតាម កាតវាចា នឹង ចិត្ត ដែលជាកុសលធម៌សម្រាប់នាំយើងទៅកាន់ភាពចុំច្រើន នឹង សុភ មង្គលដល់ជីវិតយើង។ កុំអួតហួសមាឌ នឹងអង្គុយលើចង្អៃលើកខ្លួនឯងវាមិន ប្រសើរទេ។ យើងទុកឲ្យអ្នកដទៃសរសើរនិង អួតអំពីយើងជំនួសយើងវិញទើប ប្រសើរ។

**មេរៀនទី៥ បាបកម្មច្រណែន**

## ក. និយមន័យ

តាមវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យបានឲ្យដឹងថាច្រណែនគឺជា"កាមិនសុខចិត្តដោយគេបានលើសខ្លួនឬដោយគេបាន ខ្លួនមិន បាន"។ មនុស្សចេះច្រណែនគ្នាដែលខុសពីសត្វត្រង់ថាសត្វមិនដែលគិតថា ច្រណែនចំពោះសត្វគ្នាវាទេ។ ដូចនេះយើងឃើញថា មនុស្សកើតមកនាំមកនូវ អកុសលធម៌ជាច្រើនតាមខ្លួនដែលរួមទាំងការច្រណែននេះផង។ ធម៌ច្រណែនអាចកើតឡើងគ្រប់មនុស្សមិនថាក្មេង ឬ ចាស់ នៅពេលការ

## ខ. ការលេចឡើងនៃការច្រណែន

ច្រណែនកើតឡើងហើយវាធ្វើឲ្យយើងនៅមិនស្ងៀមគឺចង់បាននេះបាននោះ មានប៉ុន្មានក៏មិនស្កប់ស្កល់។ការច្រណែនអាចបណ្តាលអោយយើងមានចិត្តល្អក់កករមិនស្អាត និង ខូចសុខភាពផ្លូវចិត្តដែលអាចបណ្តាលអោយចិត្តរវើរវាយ ឬ ក្លាយជាឆ្កួតទៀតផង។ ដូចនេះយើងគួរសិក្សាស្វែងយល់អំពីការច្រណែន ដោយរៀនរំងាប់ចិត្តច្រណែន តាមរយៈការសិក្សាព្រះធម៌ និង អប់រំចិត្តគំនិតឲ្យល្អស្អាតហើយលាចាក់នៅការច្រណែនទាំងអស់ អប់រំកាយវាចាចិត្តឲ្យប្រកបទៅដោយសីលធម៌របស់មនុស្សជាទង្វើដ៏ប្រពៃដែលយើងរាល់គ្នាគួរគប្បីធ្វើ។

## គ. លទ្ធផលនៃការច្រណែន

ជាលទ្ធផលបានត្រឹមតែការខូចខាតតាំងពីប្រយោជន៍តូច រហូតដល់ប្រយោជន៍ ធំ ព្រោះមិនចង់អោយគេបានខ្ពង់ខ្ពស់ ខ្លួនក៏ទទួលបាននូវភាពអាប់ឱនដែរ គ្រប់ ពេលរវល់តែរឿងច្រណែនគេ ភ្លេចអស់ការងារត្រូវធ្វើនិងសេចក្តីល្អត្រូវបំពេញ។ ចរិយាការប្រព្រឹត្តរបស់មនុស្សសត្វមានលក្ខណៈខុសគ្នាបុគ្គលខ្លះចូលចិត្តប្រព្រឹត្ត អំពើអាក្រក់ ជនខ្លះចំណង់ខាងការប្រព្រឹត្តធ្វើល្អត្រឹមត្រូវ។ ព្រោះតែ ការងារមនុស្ស ខុសគ្នា ទើបមនុស្សកើតមកស្ថិតក្នុងស្ថានភាពខុសៗគ្នា ការងារនិងហើយជាចលក រជំរួញឲ្យមាន ជាបែបផែនមិនស្របគ្នា ពេលខ្លះអាចត្រឹមប្រហាក់ប្រហែលគ្នា តែ មិនអាចដូចគ្នាទាំងស្រុងនោះទេ សូម្បីបងប្អូនភ្លោះពេលខ្លះក៏ខុសគ្នា។

## ឃ. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមកការច្រណែនធ្វើឲ្យយើងដេកត្រាំទុក្ខវេទនា គឺចិត្តក្តៅក្រហាយ ព្រោះឃើញគេមានចង់បាននិងគេ។ បុគ្គលច្រណែនគឺតែងតែមិនចង់ឲ្យគេបានអ្វី លើសខ្លួន ហើយមានគំនិតចង់ឲ្យគេទាបជាងខ្លួនរហូត ដែលចិត្តទាំងនោះហើយធ្វើ ឲ្យមានទុក្ខវេតនាខ្លោចផ្សា ដែលលោកពោលថាជា

បាបកម្មរបស់មនិស្ស។ បាបកម្ម នេះកើតមានតាមរយៈចិត្តចង់បានច្រើនជាងគេ ចង់មានភាពខ្ពង់ខ្ពស់ តែបើឃើញ ជនដទៃ ទទួលបានការគោរពរាប់អាន មានទ្រព្យធនវិសេសវិសាលជាងខ្លួន ក៏កើត ជាគំនិត ទើសទាល់ ចំពោះភាពរុងរឿងនោះ។ ដូចនេះ យើងគ្រប់គ្នាចូរចាំថាមនុស្ស យើងពេលកើតមកស្លាប់ទៅវិញ មិនអាចវេចខ្ចប់មាសប្រាក់ទាំងអស់ទៅបានទេ ដូច្នេះអ្នកត្រូវធ្វើអ្វីដែលខ្លួនចង់ធ្វើ ហើយសប្បាយឲ្យបានច្រើន រស់នៅឲ្យសុខ ស្រួល តែត្រូវធ្វើអ្វីដែលជាសេចក្ដីល្អ។

## មេរៀនទី៦ បាបកម្មកំណាញ់

### ក. និយមន័យ

កំណាញ់ជានាម ឬគុណនាម មានន័យថាការឈ្នះចាញ់ ដែលហួងហែងទ្រព្យ របស់ទុកមិន ចាយ ឬប្រើ ឬមិន ឲ្យសាធារណ៍ទូទៅដល់អ្នកឯទៀត (វចានុក្រមខ្មែរ សម្តេច ជួន ណាត ទំព័រ ៣៩) ។ បើតាមវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយដោយ ពុទ្ធសាសនបណ្ឌិតបានឲ្យដឹងថា ការកំណាញ់ ដែលហួងហែងទ្រព្យរបស់ទុកមិន ចាយ មិនប្រើឲ្យសាធារណ៍ទូទៅដល់អ្នកឯទៀត។ កំណាញ់ជា អកុសលធម៌មួយ បែបដែលមិនអាចធ្វើយើងមាន បងប្អូន សាច់ញាតិ រាប់អានយើងឡើយ ព្រោះធម៌ នេះបានបង្ខាំងបិទជិតទៅហើយនូវការរាប់រក និង ចែករំលែកនូវសេចក្តីសុខដែល ខ្មែរតែងតែមាន ប្រពៃណី គឺវប្បធម៌ចែករំលែក។ យើងធ្លាប់បានដឹងហើយថា ប្រជា ជនខ្មែរយើងនូវរបស់អ្វីបន្តិចបន្តួច តែងតែងតែចែកគ្នាទោះរបស់នោះតិចក្តី ច្រើន ក្តី។ នេះសបញ្ជាក់ថាខ្មែរយើងមិនមានអកុសលធម៌ គឺ ការកំណាញ់នេះទេ។

### ខ. ការលេចឡើងនៃកំណាញ់

ការរស់នៅរបស់យើងតែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ជាក់ ជាមិនខាន ដោយគ្មានបុគ្គលណាមួយអាចរស់នៅតែឯកឯងបានទេ ដូចនេះយើង មិនត្រូវមានចិត្តកំណាញ់ដោយ លាក់លៀមទុកតែខ្លួនឯងនោះទេ យើងត្រូវចេះចែក រំលែកអោយអ្នកដទៃបានសេចក្តីសុខដូចខ្លួនផង។ ទោះបីជាយ៉ាងណាក៏ដោយ យើងគួរតែចេះធ្វើអំពើជាកុសល ហើយចេះមានចិត្តជួយអ្នកដទៃ ញាតិមិត្ត ដោយ ការមិនមានចិត្តកំណាញ់នោះយើងនិងមានបងប្អូនញាតិមិត្តគោរពស្រលាញ់រាប់អានច្រើន។ ចិត្តកំណាញ់គឺជាធម្មជាតិម្យ៉ាងពោរពេញដោយក្តីលោភលន់ ប្រកាន់មុតមាំមនុស្ស សត្វ វត្ថុនិងទ្រព្យ ធននានា ហើយមិនចង់អោយវត្ថុទាំងនោះ បាត់បង់ទេ។ កំណាញ់មួយប្រភេទដែលជាប្រមុខធំក្នុងសេ ចក្តីសាបសូន្យ គឺការ កំណាញ់ជាមួយខ្លួនឯង។ ត្រង់ចំណុចនេះហើយដែលបណ្ឌិតអ្នកប្រាជ្ញនានា កំណត់ ថា នេះហើយគឺជាការធ្វើនៅសេចក្តីវិនាសដល់ខ្លួនឯង យកខ្លួនឯងធ្វើជាសត្រូវដ៏គួរ ឲ្យខ្លាច ជាងសត្រូវដទៃរាប់ពាន់លានដង។ ហើយលោកបានដាស់តឿនថា ទ្រព្យ ធន់ដែលមានហើយត្រូវចាយ វាយឲ្យបានត្រឹមត្រូវ និងស្របតាមលទ្ធភាព និងចេះ រកសេក្តីសុខដល់ខ្លួនឯង។

### គ. លទ្ធផលនៃការកំណាញ់

ទោសជាតិទាំងឡាយនឹងកើតចេញពីការកំណាញ់ត្បិតត្បៀតលាក់បំពួននេះ ក្នុងកាលបច្ចុប្បន្ន ក៏មានទៅបរលោកក៏មាន។ វាបណ្តាលឲ្យបាត់បង់ញាតិមិត្តធ្លាប់មានហើយនឹងត្រូវរស់ក្នុងស្ថានភាព

ពិបាកយ៉ាប់យឺន។ និយាយឲ្យចំគឺបានអ្វីស៊ី លាក់បំពួន ហើយបានមានទុក្ខហៅគេអោយជួយ បណ្ដាលឲ្យអ្នកប្រព្រឹត្តវិនាសអន្តរាយ។ នេះជាបាបកម្មដែលអាចបណ្ដាលឲ្យអ្នកប្រព្រឹត្តវិនាសអន្តរាយ។

## ឃ. សេចក្ដីសន្និដ្ឋាន

រួមសេចក្ដីមកធម៌កំណាញ់ជាឫសគលនៃសេចក្ដីវិនាសដែលអ្នកប្រាជ្ញ ទាំងឡាយ លោកស្អប់ខ្ពើម និង ទាំងតែពន្យល់មនុស្សជំនាន់ក្រោយឲ្យលះបង់នូវ ចិត្តកំណាញ់ចេញ ហើយខំធ្វើទានរក្សាសីល ញញឹមរាក់ទាក់ជាមួយមិត្ត សាច់ញាតិ បងប្អូន ដែលនាំមកនូវសេចក្ដីសុខដល់ខ្លួន និង សង្គមជាតិទាំងមូល។

## មេរៀនទី៧ បាបកម្មលាក់ទោសកំហុសទុក

### ក.និយមន័យ

លាក់ទោសកំហុសទុកគឺនៅពេលដែលមនុស្សយើងធ្វើអ្វីមួយខុស ហើយមិនចង់អោយគេដឹង និងមិនចេញមុខមកទទួលខុសត្រូវលើកំហុសនេះ, នៅតែព្យាយាមបិទបាំង លាក់ទុកក្នុងខ្លួននូវអំពើអាក្រក់របស់ខ្លួន មិនព្រមអោយគេដឹង។

### ខ. ការលិចឡើងនូវបាបកម្ម លាក់ទោសកំហុសទុក

ការលិចឡើងនូវទង្វើបែបនេះគឺនៅពេលដែលមនុស្សបានសាងអំពើមួយដែលអាក្រក់ ដែលមិនត្រឹមត្រូវ មិនល្អ មិនសមរម្យ ហើយមានចិត្តខ្លាចគេដឹង ខំប្រឹងលាក់ តាមវិធីសាស្រ្តអ្វីក៏ដោយអោយតែកុំអោយគេដឹង ព្រោះខ្លាចគេថាយើងមិនល្អ, ខ្លាចគេស្អប់, ខ្លាចគេមើលងាយ, ហើយខ្លាចប៉ះពាល់ដល់ កិត្តិយស ទើបមិនហ៊ានប្រឈមមុខនឹងការពិត។

### គ. លទ្ធផលនៃការលាក់ទោសកំហុសទុក

លទ្ធផលដែលទទួលបានគឺលើសពីលទ្ធផលដែលធ្វើរឿងនឹងអោយកើតឡើងទៀត ព្រោះនៅពេលដែលយើងធ្វើខុស យើងចេះទទួលខុសត្រូវ ហើយរកវិធីសាស្រ្តដោះស្រាយវា ប៉ុន្តែផ្ទុយទៅវិញអ្នកបែបជាមិនទទួលខុសត្រូវ ហើយមិនព្រមអោយគេដឹង នៅខំប្រឹងលាក់បាំងទៀត ដល់ចុងក្រោយគេដឹងគេកាន់តែស្អប់ថែមទៀត។

### ឃ. សេចក្តីសន្និដ្ឋាន

ដូច្នេះមនុស្សម្នាក់ៗ គួរគេប្បីតែជៀសវាងនូវលាក់ទោសកំហុសទុកនេះអោយបាន ដើម្បីអោយមានសេចក្តីសុខនៅក្នុងខ្លួន។

**មេរៀនទី៨ បាបកម្មអួត**

## ក. និយមន័យ

អួត គឺជាការនិយាយសរសើរខ្លួនឯង ដែលនិយាយរៀបរាប់ពីគុណសម្បត្តិអ្វីមួយរបស់ខ្លួនអោយគេបានដឹង បានឮ ហើយក្នុងគោលបំណងចង់អោយគេសរសើរខ្លួន និងបញ្ឈឺមនុស្សម្នាក់ទៀត។

## ខ. ការលិចឡើងនូវបាបកម្ម អួត

ការអួត គឺកើតនៅលើមនុស្សគ្រប់វ័យ គ្រប់កាលៈទេសៈទាំងអស់ នៅពេលដែលបុគ្គលនោះបានធ្វើអ្វីមួយដែលគិតថាខ្លួនឯងអស្ចារ្យ ដែលខ្លួនទទួលបាននូវភាពជោគជ័យ ដោយខិតខំដើរនិយាយសរសើរ លើកតំកើនខ្លួនឯង ដើម្បីអោយគេបានដឹងថាយើងពិតជាល្អ ជាមនុស្សដែលមានសមត្ថភាព និងមួយវិញទៀតគឺបានឌឺដងគ្នាដោយការនិយាយអួត។

## គ. លទ្ធផលនៃការអួត

ការអួតលទ្ធផលទទួលបានវាមិនដែលល្អទេ តែងតែមានគេស្អប់ខ្ពើម ពេលខ្លះនិយាយឡើងគេស្តាប់ឡើងធុញ, ពេលខ្លះគេមិនជឿទេ ថែមទាំងត្រូវបានគេមើលងាយ គេសើចចំអកទៀតផង, ហើយតែងតែទទួលបានផលពិបាកដល់ខ្លួនទៅវិញ។

## ឃ.សេចក្តីសន្និដ្ឋាន

ជាចុងក្រោយការនិយាយអួត,ការដែលមានមោទនភាពចំពោះខ្លួនឯងពេក គឺរមែងទទួលបាននូវផលមិនល្អដូចបាននិយាយនៅខាងលើ ហើយត្រូវគិតថាអ្នកដទៃក៏គេមានសមត្ថភាព មានគុណសម្បត្តិរបស់គេដែរ។ដូចនេះយើងត្រូវព្យាយាមចេញអោយឆ្ងាយ និងជៀសវាងនូវទង្វើនេះ ព្រមទាំងស្វែងរកសាមគ្គីភាពនិងសុខសន្តិភាពជូនសង្គមជាតិយើង។

**មេរៀនទី៩ បាបកម្មចចេស**

## ក. និយមន័យ

ចចេសគឺមានន័យសំដៅទៅលើ មនុស្សដែល, រឹងរូស, មាត់រឹង,មិនដែលស្តាប់ពីអ្វីទាំងអស់គឺតែងតែ គិតបែបណាធ្វើបែបនឹងមិនខ្វល់ពីបម្រាម ច្បាប់ វិន័យ គឺហាមមិនស្តាប់តែម្តង។

## ខ. ការលិចឡើងនូវបាបកម្ម ចចេស

ការលិចឡើងនៃការចចេសរបស់មនុស្សគឺនៅពេលដែលបុគ្គលនោះខ្វះការគិតពិចារណា មិនដែលជឿនូវអ្វីដែលគេប្រាប់។ជាមនុស្សចូលចិត្តយល់តែចិត្តខ្លួនឯង ហើយយកគំនិតរបស់អ្នកដទៃចាត់ទុកថាគ្មានប្រយោជន៍ និងមិនដែលគិតហើយយកមកពិចារណា។

## គ. លទ្ធផលនៃការចចេស

ការទទួលបានមកពីការចចេសគឺមានតែការស្តាយក្រោយ, តែងតែជួបនូវបញ្ហាដែលគេបាននិយាយប្រាប់, ដល់ជួបបញ្ហានៅនឹងមុខបានដឹងថាអ្វីជាអ្វី, ចុងក្រោយមានតែវិនាសខ្លួនឯង, លំបាកតែខ្លួនឯង, ហិនហោចនូវរបស់អ្វីមួយពីខ្លួន។

## ឃ. សេចក្តីសន្និដ្ឋាន

ដូចនេះ ការចចេសគឺជាបាបកម្មមួយដែលធ្វើអោយអ្នកដទៃឈឺចាប់ ទាំងផ្លូវកាយនិងផ្លូវចិត្តគឺសិទ្ធសឹងតែជាបាបកម្មទាំងអស់។ ដូច្នេះហើយមនុស្សទាំងអស់គ្នាគួរតែជៀសវាងអោយបាននូវអំពើបាបកម្មទាំងឡាយក៏ដូចជាបាបកម្មមួយនេះផង។

## មេរៀនទី១០ បាបកម្មការប្រជែងយកឈ្នះ

### ក. និយមន័យ

បាបកម្មជាអំពីដែលមនុស្សរាល់គ្នាគួរជៀសវាង ដែលបាបកម្មទាំងនោះជាអកុសលកម្មរបស់យើងដែលបានប្រព្រឹត្តទៅហើយនោះ ហើយមកដល់ត្រង់នេះយើងនឹងនាំគ្នាសិក្សាអំពីបាបកម្មមួយទៀតដែលមានឈ្មោះថា ប្រជែងយកឈ្នះ ។ បើតាមវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យបានឲ្យដឹងថា ការប្រជែងយកឈ្នះ គឺជាការដណ្ដើមប្រជែងកាត់មុខគ្នា, ដណ្ដើមយកឈ្នះ ដើម្បីបានលើគេ ឬ លើសគេ បានឈ្នះគេ ជាដើម ។

### ខ. ការលេចឡើងនៃការប្រជែងយកឈ្នះ

ការរស់នៅរបស់មនុស្សសព្វថ្ងៃពោរពេញទៅដោយការប្រជែងគ្នាច្រើនណាស់ មិនថាទីណាទេ គ្រប់ស្ថាបនទាំងស្ថាបន រដ្ឋ សាសនា និង ឯកជន ។ សូម្បីតែការសិក្សាក៏មានការប្រកួតប្រជែងគ្នាដើម្បីទទួលរង្វាន់ ឬ ចំណាត់ថ្នាក់ល្អ ។ ដោយសារមានការប្រជែងគ្នានេះហើយទើប សង្គមក៏មានការរីកចំរើន និង អភិវឌ្ឍទៅមុខជាលំដាប់ ។ ដូចតួយ៉ាងវិស័យសិក្សា បើសិស្សមានការប្រកួតប្រជែងនោះ យកឈ្នះចាញ់នោះ នៅពេលនោះនិស្សិត ឬ សិស្សនឹងមានការខិតខំប្រឹងប្រែងរៀនសូត្រ ការខិតខំប្រឹងប្រែងនេះនឹងធ្វើឲ្យនិស្សិត និង សិស្សទាំងអស់នោះមានចំណេះដឹងបរិបូរ ពេញលេញក្នុងខ្លួនដើម្បីប្រជែងយកឈ្នះសិស្ស និស្សិតដទៃទៀតបាន ។ នៅពេលការខិតខំប្រឹងប្រែងប្រកបដោយវិចារណញាណនោះ ការទទួលបាននូវជោគជ័យ និង ផលសម្រេចនឹងផ្តល់ជាវិជ្ជមានដល់បុគ្គលអ្នកខិតខំ ។ ប៉ុន្តែផ្ទុយមកវិញ ការប្រជែងយកឈ្នះដោយគ្មានវិចារណញាណ គឺការប្រជែងយកស្លាប់យករស់មកដាក់ខ្លួន ឬ មិនមាននរណាឈ្នះក្រៅពីអញនោះការប្រជែងនោះនឹងស្ថិតនៅគោលអវិជ្ជមាន គឺនឹងផ្តល់បាបដល់យើង ដែលយើងបានឲ្យការប្រជែងយកឈ្នះបែបនេះថាជាបាបកម្ម ។

### គ. លទ្ធផលនៃការប្រជែងយកឈ្នះ

ហេតុដែលយើងចាត់ទុកការប្រជែងយកឈ្នះជាបាបកម្មមួយនោះ ព្រោះការប្រជែលតែងតែនាំមកនូវការតូចចិត្ត ឬ ក្តៅក្រហល់ក្រហាយដល់បុគ្គលអ្នកប្រជែងយកឈ្នះនោះដោយហេតុនៃផលដែលទទួលបានមិនសមដូចបំណង ហើយម្យ៉ាងទៀតគូរបដិបក្សនឹងមានសេចក្តីឈឺចុកចាប់ក្នុងចិត្តនៅពេលគេមិនទទួលបានដូចបំណង ។ ការប្រជែងយកឈ្នះនេះទោះបីមានឧបសគ្គយ៉ាងណាក៏ខិតខំពុះពារដើម្បីទទួលជោគជ័យ ហើយពេលខ្លះរហូតហួសសមត្ថភាព ឬ ដល់ស្លាប់ទៀត ក៏ថាបាន ។ ដែលថាការប្រជែងយកឈ្នះបង្កជាបាបកម្មនោះព្រោះការប្រកួតប្រជែងយកឈ្នះឲ្យខានតែបានទោះបីប្រើ

ល្បិចកលយ៉ាងណាក៏ដោយ ហើយពេលខ្លះរហូតដល់បោកប្រាស់គេ ឬថែមទាំងកាប់សំលាប់គេក៏មាន ដើម្បីតែការយកឈ្នះតែមួយមុខគត់ ។

## ឃ. សេចក្តីសន្និដ្ឋាន

នៅពេលយើងដឹងថាការប្រជែងយកឈ្នះចាញ់ គឺជាកម្មអាក្រក់ដែលផ្តល់ឲ្យយើងនូវក្តីវិនាស និង ការឈឺចុកចាប់ទាំងផ្លូវអារម្មណ៍ ទាំងផ្លូវកាយ ដូចនេះយើងត្រូវជៀសវាងឲ្យផុតដើម្បីរស់នូវក្នុងក្តីសប្បាយ គឺសេចក្តីសុខនោះឯង ដូចដែលយើងមិនប្រជែងយកឈ្នះក្នុងផ្លូវអាក្រក់គឺបាបកម្មនៃការប្រជែងយកឈ្នះទាល់តែបាន ។

## មេរៀនទី១១ បាបកម្មទុកខ្លួនជាវិសេសវិសាលជាងគេ

### ក. និយមន័យ

ពីមួយថ្ងៃទៅមួយថ្ងៃ ការរស់នៅរបស់យើងប្រកបដោយការប្រព្រឹត្តមានកម្មជា កុសលកម្ម និង អកុសលកម្មដែលជាធម៌របស់មនុស្ស ។ យ៉ាងណាការមានអំនួតគឺការទុកខ្លួនជាវិសេសវិសាលជាងគេ គឺជាបាបកម្មដ៏ធំរបស់មនុស្ស ដូចពាក្យចាស់លោកពោលថា ចេះឯងឲ្យក្រែងចេះគេ ដូចនេះការទុកខ្លួនជាវិសេសវិសាលជាងគេ គឺជាបាបកម្មមួយរបស់មនុស្សដែលប្រកបដោយអវិជ្ជាដែលមានរួមរឹតនិងផ្សំដោយលោភៈ ទោសៈ និង មោហៈ ជាឫសគល់នៃសេចក្តីទុក ។ បើតាមវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យបានឲ្យដឹងថា ការទុកខ្លួនជាវិសេសវិសាលជាងគេ គឺជាការទុកខ្លួនថាល្អប្លែក ឬ ប្រសើរដាច់គេ មិនមាននរណាប្រសើរជាង វិសេសក្រៃលែងជាង, និង វិសេសជាងគេ ។

### ខ. ការលេចឡើងនៃការទុកខ្លួនជាវិសេសវិសាលជាងគេ

តាមពិតការកើតឡើងនៃមនុស្ស ឬ បើនិយាយឲ្យចំគឺការកើតចាប់បដិសន្ធិរបស់មនុស្សមិនបានយកអ្វីមកជាមួយទេ ហើយយើងមិនដែលឃើញនរណាម្នាក់កើតមកយករបស់មាសប្រាក់មកជាមួយផង មានតែខ្លួនទទេ ។ ប៉ុន្តែនៅពេលយើងកើតមកជាមនុស្សបែរជាមានអំនួតគឺការទុកខ្លួនជាវិសេសវិសាលជាគេទៅវិញ ហើយថែមទាំងប្រព្រឹត្តនូវអំពើបាបមានការទុកខ្លួនជាធំ ប្រសើរដាច់គេដែលជាបាបកម្មមួយដ៏លាមកច៍ ម្យ៉ាងទៀតអកុសលកម្មនឹងនាំមនុស្សអ្នកប្រព្រឹត្តទៅរកសេចក្តីវិនាសអន្តរាយ ។ ការទុកខ្លួនជាវិសេសវិសាលជាគេវាទៅតាមនិស្ស័យរបស់មនុស្ស ព្រោះមនុស្សខ្លះមាននិស្ស័យល្អ ហើយមនុស្សពួកខ្លះមាននិស្ស័យអាក្រក់គឺការទុកខ្លួនជាធំវិសេសវិសាលជាអ្នកដទៃ ហើយគេគិតថានៅក្នុងលោកនេះមានតែគេគឺ គ្មាននរណាល្អជាងគេ និង ក្រៃលែងជាងគេទេ ។

ផ្ទុយមកវិញបើនរណាម្នាក់មានការគិតត្រឹមត្រូវមិនលើដំកើងខ្លួនឲ្យហួស វិសេសវិសាលជាងគេនោះបុគ្គលនោះនឹងដល់នូវសេចក្តីសុខ និង មានការរាប់រកពីមនុស្សរាល់គ្នា ហើយមានមិត្តច្រើនជាមិនខានព្រោះតែការមិនទុកខ្លួនជាធំ និង វិសេសវិសាលជាងគេ ហើយយើងគួរតែគិតថាមនុស្សទាំងអស់រស់នៅដោយភាពស្មើភាពគ្នាក្នុងជីវភាពរស់នៅតាមធម្មជាតិរបស់សត្វ ។ ការចាត់ទុកខ្លួនជាធំ ហើយវិសេសវិសាលជាគេគឺជាបាបកម្ម ព្រោះគំនិតនេះមិនស្គាល់ខ្លួនឯង ហើយស្ថិតនៅងងឹតងងល់ មើលមិនឃើញពីតម្លៃអ្នកដទៃ ម្យ៉ាងទៀតចេះតែថាខ្លួនឯងមានគុណសម្បត្តិគ្រប់យ៉ាងដោយគ្មាននរណាម្នាក់មាន ។ បើចង់ធ្វើអ្វីបែរជាថាគេមិនដល់អញ ហើយគិតថាមនុស្សរាប់គ្នាសុទ្ធតែមនុស្សល្ងង់ បើចេះក៏ចេះមិនដល់អញ បើធ្វើក៏ធ្វើមិនដល់អញ និយាយជារួមអ្នកដទៃសុទ្ធតែអន់ជាងខ្លួនរហូត ។

### គ. លទ្ធផលនៃការទុកខ្លួនជាវិសេសវិសាលជាងគេ

ទោសទាំងឡាយងាយនឹងឧប្បត្តិឡើង ដោយសារតែការវាយឫក ឲ្យតម្លៃខ្លួនហួសប្រមាណ មិនមាននរណាគេហ៊ានសេពគប់ ព្រោះតែខ្លួនវិសេសវិសាលពេក ខ្លួនទាបដៃខ្លីឈោងមិនដល់ ម្លោះហើយជនដែលសម្គាល់ ថាអាត្មាវិសេសវិសាលក៏ដល់នូវក្តីឯកោ ឥតមានបរិវារតាមហែហម សាបសូន្យចាកលាភទាំងពួង ។

### ឃ. សេចក្តីសន្និដ្ឋាន

យើងត្រូវជៀសឲ្យផុតអំពីបាបកម្មមួយនេះដើម្បីរួមរស់នៅជាសុខ ថែមទាំងមានសេចក្តីកោតក្រែងពីមនុស្សរាល់គ្នាព្រោះការមិនចាត់ទុកខ្លួនជាធំវិសេសវិសាលជាងគេ យើងត្រូវចេះបន្ទាបខ្លួនដាក់ខ្លួន ហើយត្រូវគិតថាភ្នំមួយខ្ពស់នៅមានភ្នំមួយខ្ពស់ជាងនេះទៀត ត្រូវចេះឯងឲ្យក្រែងចេះគេ។ តាមពាក្យចាស់បុរាណលោកតែងតែពោលថា ងើយស្កកអោនដាក់គ្រាប់ ព្រោះលោកចង់ប្រៀនប្រដៅកូនចៅលោកឲ្យចេះក្រែងអ្នកដទៃ កុំលើកកំពស់ខ្លួនហួសហេតុដែលជាហេតុនាំមកនូវសេចក្តីអន្តរាយ និងទុក្ខវេទនាផ្សេងៗ ។ ដើម្បីឆ្ពោះទៅរកសេចក្តីសុខ និង សម្បូរញាតិមិត្ត យើងមិនត្រូវប្រព្រឹត្តនូវបាបធម៌គឺការទុកខ្លួនជាវិសេសវិសាលជាងគេឡើយ ។

## មេរៀនទី១២ បាបកម្មមើលងាយគេ

### ក. និយមន័យ

មកដល់ត្រង់នេះយើងឈាន់ចូលនូវបាបកម្មមួយទៀតដែលយើងឲ្យឈ្មោះថាមើលងាយគេ ។ ហេតុដែលយើងមើលងាយគេមានច្រើនយ៉ាងតាមការគិត និង ទង្វើរបស់យើង ខ្លះតាមផ្លូវកាយ ហើយខ្លះតាមផ្លូវចិត្ត ។ ការមើលងាយគេត្រូវបានចាត់ទុកថាជាបាបកម្មព្រោះនៅពេលយើងបញ្ចេញវានឹងឲ្យផលជាអវិជ្ជមាន គឺផលជាទុក្ខ និង អន្តរាយវិនាស ជាធម៌អកុសលរបស់បុគ្គលល្ងង់ពោលគឺអវិជ្ជាជន ។ បើតាមវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យបានឲ្យដឹងថា ការមើលងាយគេ គឺជាការមើលឃើញថាងាយ, មើលយល់ថាងាយ គឺមើលទៅឃើញថាងាយស្តី ងាយថា ងាយធ្វើ ជាដើម ។ មើលងាយមើលថោក មើលឃើញថាងាយឃើញថាថោក គឺឃើញថាមិនក្រមិនមានតម្លៃ រួមសេចក្តីមកការមើលងាយគេ គឺការមិនឲ្យតម្លៃដល់អ្នកដទៃដោយគិតថាគេថោកជាងខ្លួន ។

### ខ. ការលេចឡើងនៃការមើលងាយគេ

បាបកម្មជាអំពើមួយដែលផ្តល់ឲ្យយើងមកវិញនូវសេចក្តីទុក្ខវេទនា និង ការមើលងាយមើលទោកពីមនុស្សគ្រប់រូប និង សង្គម ដោយសារអកុសលកម្មរបស់យើង គឺការមើលងាយអ្នកដទៃ ។ ប្រាកដណាស់ថាគ្មាននរណាម្នាក់ចង់ឲ្យគេមើលងាយទេ រួមទាំងរូបយើងផ្ទាល់ ។ នៅពេលគេមើលងាយយើងៗតែងតែខឹងសម្បា និង មិនចូលចិត្ត ហើយពេលខ្លះថែមទាំងធ្វើអំពើជាអកុសលផ្សេងៗ ដែលបណ្តាលឲ្យអ្នកដែលមើលងាយយើងទទួលរងនូវសេចក្តីទុក្ខ និង វិនាសទ្រព្យសម្បត្តិជាដើម ។ ដូចនេះយើងឃើញថាការមើលងាយអ្នកដទៃ បណ្តាលឲ្យមានគ្រោះថ្នាក់ផ្សេងៗ ពេលខ្លះរហូតដល់ស្លាប់ក៏មាន ។

ការមើលងាយគេ ក៏ដូចជាការមិនឲ្យតម្លៃអ្នកដទៃព្រោះយើងមានអកុសលធម៌មួយគឺ មោហៈ ដែលយើងតែងតែថាវង្វេងៗព្រោះខ្លួនមានអំនួតទៅលើអ្វីដែលខ្លួនមិនមាន ដូចជាការមើលងាយថាមេរៀនតិច ទន្ទេញតែបន្តិចក៏ចាំអស់ហើយៗក៏រង់ចាំថ្ងៃស្អែក នៅពេលស្អែករហូតមេរៀននោះក៏មិនចាំ ទាំងអស់នេះបណ្តាលឲ្យប្រឡងធ្លាក់ ។ ការប្រឡងធ្លាក់ជាការវិនាស និង ខូចខាតនូវផលប្រយោជន៍ដែលបណ្តាលមកពីការមើលងាយដែលជាធម៌អកុសលពោលគឺ បាបកម្មនៃការមើលងាយនោះឯង ។

### គ. លទ្ធផលនៃការមើលងាយគេ

គ្រប់មនុស្សទាំងអស់សុទ្ធតែចង់ឲ្យគេឲ្យតម្លៃដល់ខ្លួន ទោះបីបុគ្គលនោះមានរូបរាងតូចតឿ អាក្រក់ សខ្មៅ ហើយមានសម្បទានមិនគ្រប់គ្រាន់ក៏ដោយ ។ ការរស់នៅប្រកបដោយតម្លៃ ថ្លៃថ្នូរ និង មានកេតិយសនោះវាជាក្តីបំណងរបស់មនុស្សគ្រប់រូប ប៉ុន្តែដើម្បីមានរបស់ទាំងនេះយើងគួរគប្បីកសាងដោយខ្លួនឯង គឺស្វែងរកនូវតម្លៃគឺកេរ្តិ៍ឈ្មោះដោយការមិនមើលងាយអ្នកដទៃ ។ ពិតណាស់ហើយថាបើ

បុគ្គលប្រព្រឹត្តនូវធម៌បែបណារមែងទទួលនូវធម៌បែបនោះ ។ ធម៌នូវក្នុងទីនេះរួមមានកុសលធម៌ និង អកុសលធម៌ដែលមនុស្សតែងតែប្រកន់យក ដោយអ្នកខ្លះប្រព្រឹត្តនូវកុសលធម៌ (ធម៌ល្អ) និង អ្នកខ្លះ ប្រព្រឹត្តនូវអកុសលធម៌ (ធម៌អាក្រក់)ពោលគឺការមើលងាយគេជាដើម ។ មនុស្សដែលចូលចិត្ត មើលងាយអ្នកដទៃរមែងទទួលនូវការមើលងាយពីអ្នកដទៃមកវិញជាំមិនខាន ។ បើយើងញញឹមទៅរក គេៗនឹងញញឹមមករកយើងវិញ តែបើយើងមើលងាយគេៗនឹងមើលងាយយើងវិញ ដូចព្រះសម្មាសម្ពុទ្ធ ពោលថា បុគ្គលដាំនូវពូជណានឹងបាននូវផលនោះ ។ បើយើងដាំអំពើល្អយើងនឹងបានផលគឺអំពើល្អមក វិញ តែបើយើងដាំនូវអំពើអាក្រក់យើងនឹងទទួលបាននូវផលគឺអំពើអាក្រក់មកវិញ ។

## ឃ. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីយើងបានយល់ដឹងអំពីផលនៃការមើលងាយគេ យើងទាំងអស់គ្នាគួរជៀសវាងឲ្យផុត ពីបាបកម្មនេះដើម្បីចាប់យកនូវការមិនមើលងាយគេ ដែលជាធម៌នាំមកនូវសេចក្តីសុខចម្រើន សប្បុរ សប្បាយដែលផ្ទុយពីការមើលងាយគេដែលនាំមកនូវសេចក្តីក្រហលក្រហាយ និង ទុក្ខវេទនាមកដល់ យើងវិញ ។អំពើមានប្រយោជន៍គួរគប្បីធ្វើ វិជ្ជាចេះស្ទីគួរខំបំពេញ ។ ការមើលងាយគេគួរលះបង់ដើម្បី តម្រង់ផ្លូវទៅរកសេចក្តីសុខដោយការប្រព្រឹត្តនូវការមិនមើលងាយគេ ។ ការសិក្សាពីបាបកម្មទាំងអស់ នេះដែលអាចនាំយើងទៅរកផ្លូវត្រូវមួយ ដែលមនុស្សដូចគ្នាទទួលស្គាល់ថាជាមនុស្សល្អគួររាប់រក ដើម្បី សេចក្តីសុខចម្រើន ។

## មេរៀនទី១៣ បាបកម្ម ស្រវឹងលង់ក្នុងគំនិត

### ក. និយមន័យ

ស្រវឹងលង់ក្នុងគំនិតមានន័យបថា ការលង់ ឈ្លក់វង្វេងក្នុងការគិតនិងក្ដីសុបិត្តរបស់ខ្លួន, ជឿស៊ប់ចំពោះខ្លួនឯង ហើយតែងតែគិតថាគំនិតរបស់ខ្លួនល្អឥខ្ចោះ ដែលគ្មានអ្នកណាប្រៀបបាន។

### ខ. ការលិចឡើងនូវបាបកម្ម ស្រវឹងលង់ក្នុងគំនិត

ការលិចឡើងនៃបាបកម្មនេះគឺ ជឿជាក់លើផ្នត់គនិតខ្លួនឯងពេក ព្រមទាំងមិនស្ដាប់យោបល់របស់អ្នកណាទាំងអស់។លើសពីនេះ កើតឡើងដោយសារខ្វះការគិតពិចារណា ដោយគិតថាគំនិតរបស់ល្អត្រឹមត្រូវជានិច្ច ព្រមទាំងមិនយល់ពីគុណសម្បត្តិនៃគំនិតរបស់អ្នកដទៃចំពោះខ្លួនឯង ជាហេតុធ្វើអោយពួកគេបាត់បង់ការត្រួតពិនិត្យ និងការពិចារណាកលក្នុងខ្លួន។

### គ. លទ្ធផលនៃបាបកម្មស្រវឹងលង់ក្នុងគំនិត

លទ្ធផលដែលទទួលបានពីបាបកម្មស្រវឹងលង់ក្នុងគំនិតគឺមានការស្ដាយក្រោយ និងមានវិប្បដិសារីអស់មួយជីវិត ពីព្រោះមុននឹងធ្វើអ្វីមួយត្រូវមានការគិតពិចារណាជាមុនសិន និងត្រូវមានការផ្លាស់ប្តូរគំនិតជាមួយអ្នកដទៃ និងយកយោបល់គេមកគិតខ្លះបានធ្វើទៅបានល្អ។

### ឃ. សេចក្ដីសន្និដ្ឋាន

ដូច្នេះមនុស្សម្នាក់ៗគួរតែចេះស្ដាប់ហេតុផលរបស់គេ,គិតពិចារណាហេតុផលរបស់គេនិងជៀសវាងនូវអំពើបាបទាំងនេះ ព្រោះវាជាទង្វើខុសនូវគន្លងដែលមិនល្អ។

**មេរៀនទី១៤ បាបកម្ម ធ្វេសប្រហែស**

**ក.និយមន័យ**

ការធ្វេសប្រហេស គឺជាការមិនយកចិត្តទុកដាក់ក្នុងការធ្វើអ្វីមួយដែលត្រូវធ្វើ, ធ្វើដោយអោយរួចពីដៃ ធ្វើអោយតែបាន ឬជាការធ្វើដោយមិនប្រុងប្រយ័ត្ន ហើយមិនបានគិតពីការងារដែលកំពុងធ្វើនោះ។

**ខ. ការលិចឡើងនៃបាបកម្ម ធ្វេសប្រហែស**

ការធ្វេសប្រហែសគឺកើតឡើងនៅពេលដែលមនុស្សណាម្នាក់ធ្វើអ្វីមួយដែលមិនប្រុងប្រយ័ត្ន ហើយមិនយកចិត្តទុកដាក់ក្នុងការងារដែលខ្លួនដែលកំពុងធ្វើ។មួយវិញទៀតធ្វើការងារបណ្តែតបណ្តោយមិនព្រមធ្វើអោយហើយ, ប្រងើយកន្តើយទៅការងារដែលខ្លួនកំពុងធ្វើ, ពេលខ្លះមិនធ្វើអោយគ្រប់ជ្រុងជ្រោយដែលអាចធ្វើអោយមានកំហុស និងចន្លោះនៅថ្ងៃក្រោយ

**គ. លទ្ធផលនៃបាបកម្មធ្វេសប្រហែល**

លទ្ធផលគឺមិនដែលបាននូវអ្វីដែលល្អសម្រាប់ខ្លួន និងគ្រួសារឡើយ តែងតែបង្កើតនូវបញ្ហារាល់ពេល។បើធ្វើការងារនៅក្រុមហ៊ុនរបស់គេ ច្បាស់ជាមានគេស្តីបន្ទោសហើយ, មិនសូវមានការទុកចិត្តពីមនុស្សដែលដាក់ការងារអោយយើងធ្វើ។មួយវិញទៀត អាចនឹងត្រូវវិនាសអស់ទ្រព្យសម្បត្តិក៏មាន ព្រោះគេមិនដែលគិតពិចារណានិងប្រយ័ត្នក្នុងការថែរក្សាវា ព្រមទាំងមានវិប្បដិសារីក្នុងជីវិត។

**ឃ. សេចក្តីសន្និដ្ឋាន**

មនុស្សម្នាក់ៗកើតមកហើយតែងតែមានកំហុស ឫការធ្វេសប្រហែសនេះឯង ដូច្នេះដើម្បីអោយកំហុសរបស់ខ្លួនបានប្រសើរឡើង គឺយើងត្រូវធ្វើយ៉ាងណាអោយចេះកែកំហុស ហើយព្យាយាមធ្វើអ្វីដែលល្អដើម្បីប៉ះប៉ូវនូវកំហុសឆ្គងទាំងឡាយដែលបានប្រព្រឹត្តចោលៗអោយអស់ ទើបកើតមានឡើងនូវ សុភមង្គល។

**មេរៀនទី១៥ បាបកម្ម ជោរ**

## ក.និយមន័យ

មានន័យថាសំដៅទៅលើ មនុស្សដែលមានចិត្តទន់ជ្រាយ នៅពេលដែលគេប្រើពាក្យសរសើរ បេៀបបញ្ចោ ហើយមានអាការៈ និងលក្ខណះ ឬសភាពរីករាយ ហើយគិតនឹងថាពាក្យនឹងល្អប្រសើរ សម្រាប់ខ្លួនណាស់។

## ខ. ការលិចឡើងនៃបាបកម្ម ជោរ

បាបកម្មជោរគឺ កើតឡើងនៅពេលដែល មនុស្សដែលធាប់សប្បាយរីករាយ ភ្លើតភ្លើន ត្រេកអរខ្លាំង ចំពោះពាក្យដែលគេបានសរសើរ និយាយល្អអោយ បេៀបបញ្ចោយើង ហើយមិនបានគិតពិចារណា ហើយជោរទៅតាមផ្លូវមិនល្អតាមពាក្យសម្ដីផ្សេងៗ។

## គ. លទ្ធផលនៃបាបកម្មជោរ

លទ្ធផលដែលទទួលបានពីការជោរ គឺអាចធ្វើអោយពួកគេមានការស្ដាយក្រោយគ្រប់ពេលវេលា ដោយសារតែការជឿតាមការបញ្ចោ និងងាយរងនូវការលួមលោងរបស់គេ, ជនខិលខូច, ងាយត្រូវគេ បោកប្រាស់ ហើយធ្វើអោយយើងមានបញ្ហា ជាមិនខាន។

## ឃ. សេចក្ដីសន្និដ្ឋាន

ជោរគឺជាបាបកម្មមួយដែលនាំអោយចិត្តមនុស្សកើតនូវសេចក្ដីក្រហល់ក្រហាយនៅក្នុងខ្លួន ដែល ជាហេតុធ្វើអោយពួកគេប្រព្រឹត្តនូវអំពើដែលនាំអោយសៅហ្មងក្នុងចិត្ត។ ដូច្នេះមនុស្សម្នាក់ៗគួរតែ ព្យាយាមយ៉ាងណា លុបបំបាត់នូវបាបកម្មជោរនៅក្នុងចិត្តរៀងៗខ្លួន។

## សេចក្តីសន្និដ្ឋាន

ឆ្លងតាមការបកស្រាយខាងលើអំពីបាបកម្មទាំង១៥ប្រការ យើងទាំងអស់គ្នា បានយល់ដឹងច្រើនជាងមុនអំពីបាប នឹងបុណ្យដែលមនុស្សបានសាងលើយក៏បាន ឃើញហើយដែរអំពីលទ្ធផលនៃការសាងបាបកម្មផងដែរ។ ជាការពិតមានហើយ ផលដែលទទួលបានពីការសាងបាបកម្ម គឺមានតែគ្រោះអន្តរាយ វិនាសកម្ម ភាព ហិនហោច ក៏ដូចជាខាតបង់តែប៉ុណ្ណោះ ហើយលើសពីរនេះអាចនាំទុក្ខដល់ខ្លួននិង អ្នកដទៃថែមទៀតផង។ ដូច្នេះ ដើម្បីចៀសវាងការកសាងបាបកម្មនឹងរស់នៅ ប្រកបដោយសេចក្តីសុខនិងសន្តិភាពយើងគ្រប់គ្នាគប្បីប្រកាន់ខ្ជាប់នឹងអនុវត្តន៍ឲ្យ បាននូវ

- សីលធម៌២ប្រការ : មេត្តា និង ករុណា
- មនុស្សធម៌៥ប្រការ : មុសាវាទ និងសុរាមេរ័យ បាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ
- សុជីវធម៌៦ប្រការ :ការស្គាល់ហេតុផលគួរមិនគួរការស្គាល់ឋានៈខ្លួននិងអ្នកដទៃការស្គាល់ប្រមាណជីវភាព ការស្គាល់កាលពេទ្យវេលា ការស្គាល់ប្រជុំជននិងទីប្រជុំ និងការស្គាល់មិត្តសំលាញ់
- វិប្បៈ៤ប្រការ : អាចារវិប្បៈ លិង្គវិប្បៈ និងបញ្ញាវិប្បៈ
- វឌ្ឍនៈ៤ប្រការ : អាចារវឌ្ឍនៈ ទស្សនីយភាវវឌ្ឍនៈ លិង្គវឌ្ឍនៈ និងបញ្ញាវឌ្ឍនៈ។

# ឯកសារពិគ្រោះ


- ដៀប សុផល អរិយធម៌ខ្មែរ គ.ស២៥៥៤
- សម្តេចព្រះសង្ឃរាជ ជួន ណាត វចនុក្រមខ្មែរ ភាគ១,២ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧
- ភិក្ខុ ប៉ាវ ខាត់ វិរិយបណ្ឌិតតោ ស្រីហេបតោបរទេស ភាគទី១,២,៣,៤
- នួន ប៊ុត និង ជុំ មួង សៀវភៅប្រមូលសុភាសិតខ្មែរ សមាគមន៍សម្តេចជួន ណាតគ.ស ២០០៧
- អ៊ូង កុសល ថ្ងៃអូនអស់សង្ឃឹម
- លី សុវីរ ប្រពៃណីជាតិខ្មែរ បោះពុម្ពលើកទី២ គ.ស២០១០ ព.ស២៥៥៤
- លុយ សុវណ្ណា រឿងអង្គុលិមាល៍ ឆ្នាំ២០០៥
- សៀវភៅប្រជុំរឿងព្រេងខ្មែរ